# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០៩២ ក.ប/ប្រ.ក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសរួមលេខ១០០៩ សហវ-ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសលេខ១៩៥ កប-ប្រក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្តីពីបណ្ណការងារ និងសៀវភៅ ការងារជនបរទេស របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងលិខិតលេខ១៣៣ សជណ.អវ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

# សម្រេច

## ប្រការ ១.–

ត្រូវបានដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មបរទេស (The Foreign Workers Centralized Management System) ដើម្បីគ្រប់គ្រងការប្រើប្រាស់ហត្ថពលកម្មបរទេសនៅកម្ពុជាតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម តាមរយៈគេហទំព័រ www.fwcms.mlvt.gov.kh ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ នេះ។

## ប្រការ ២.–

វិនិយោគិន ក្រុមហ៊ុន រោងចក្រ សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់ពលកម្មបរទេសត្រូវបំពេញបែបបទស្នើសុំកូតាប្រើប្រាស់ហត្ថពលកម្មបរទេសតាមប្រព័ន្ធទិន្នន័យស្វ័យប្រវត្តិកម្មថ្មីនេះ ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ តទៅ។

ជនបរទេសដែលចូលមកប្រកបមុខរបរណាមួយនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញបែបបទស្នើសុំ "បណ្ណការងារ និងសៀវភៅការងារជនបរទេស" តាមប្រព័ន្ធទិន្នន័យស្វ័យប្រវត្តិកម្មថ្មីនេះចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ តទៅ ។

ក្នុងករណីចាំបាច់នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ឬមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈអាចស្នើសុំឱ្យម្ចាស់សំណើមកបង្ហាញខ្លួន ឬផ្តល់ឯកសារចាំបាច់នានា។

## ប្រការ ៣.–

អនុញ្ញាតឱ្យក្រុមហ៊ុន អ៊ី-សឹលូសិន (ខេមបូឌា) E-Solutions (Cambodia) Co., Ltd. យកកម្រៃទ្រទ្រង់៖

- ចំនួន ៣០(សាមសិប)ដុល្លារអាមេរិក ក្នុងមួយសំណើ បន្ថែមលើកម្រៃសេវាសាធារណៈសម្រាប់ការស្នើសុំកូតាប្រើប្រាស់កម្លាំងពលកម្មបរទេស ដោយត្រូវបង់តាមប្រព័ន្ធធនាគារ
- ចំនួន ៣០(សាមសិប)ដុល្លារអាមេរិក ក្នុងជនបរទេសម្នាក់ បន្ថែមលើកម្រៃសេវាសាធារណៈសម្រាប់ការស្នើបណ្ណការងារ/សៀវភៅការងារជនបរទេសថ្មីមួយ ឬពន្យាបណ្ណការងារ/សៀវភៅការងារជនបរទេសមួយ ដោយត្រូវបង់តាមប្រព័ន្ធធនាគារ។

កម្រៃទ្រទ្រង់បន្ថែមដែលបង់ទៅក្រុមហ៊ុន អ៊ី-សឹលូសិន (ខេមបូឌា) គឺដើម្បីក្រុមហ៊ុន៖

១. រៀបចំប្រព័ន្ធទិន្នន័យគ្រប់គ្រងកម្លាំងពលកម្មថ្មីនេះ កសាងហេដ្ឋារចនាសម្ព័ន្ធ បំពាក់សម្ភារបណ្តុះបណ្តាលមន្ត្រី ដើម្បីដាក់ឱ្យដំណើរការការិយាល័យច្រកចេញចូលតែមួយ។

២. ទ្រទ្រង់ដំណើរការបញ្ចូលទិន្នន័យ និងការគ្រប់គ្រងទិន្នន័យកម្មករនិយោជិតខ្មែរ ដែលធ្វើការងារនៅតាមក្រុមហ៊ុន រោងចក្រ សហគ្រាសគ្រឹះស្ថាននានាក្នុងព្រះរាជាណាចក្រកម្ពុជា (ដោយមិនគិតកម្រៃសេវាទ្រទ្រង់បន្ថែម) ដើម្បីធានានូវអតីតភាពរបស់កម្មករនិយោជិតខ្មែរ។

៣. ទ្រទ្រង់ដំណើរការប្រព័ន្ធគ្រប់គ្រងទិន្នន័យអធិការកិច្ចការងារ និងផ្គត់ផ្គង់បរិក្ខារអេឡិកត្រូនិកចល័តដល់មន្ត្រីអធិការកិច្ចការងារក្នុងអំឡុងពេលចុះធ្វើអធិការកិច្ចការងារ សំដៅបង្កើនប្រសិទ្ធភាព គុណភាព

និងលទ្ធភាពត្រួតពិនិត្យជាប្រព័ន្ធនូវប្រវត្តិលក្ខខណ្ឌការងាររបស់ក្រុមហ៊ុន រោងចក្រ សហគ្រាសគ្រឹះស្ថាននីមួយៗ។

៤. ផលិតបណ្ណការងារ/សៀវភៅការងារជនបរទេស និងសេវាផ្ញើបណ្ណការងារ/សៀវភៅការងារជនបរទេសជូនសាមីជន។

៥. សាងសង់អគារច្រកចេញចូលតែមួយថ្មី ដែលមានកម្ពស់៣ជាន់ ស្មើនឹង៨២៨ (ប្រាំបីរយម្ភៃប្រាំបី) ម៉ែត្រក្រឡា។

**ប្រការ ៤ .-**

ក្នុងការបំពេញពាក្យស្នើសុំបណ្ណការងារ/សៀវភៅការងារជនបរទេសថ្មី ឬពន្យាបណ្ណការងារ/សៀវភៅការងារជនបរទេស ជនបរទេសអាចប្រើប្រាស់វិញ្ញាបនបត្រសុខភាពផ្ទាល់ខ្លួន ដែលកំពុងមានសុពលភាព ប៉ុន្តែត្រូវស្នើសុំបញ្ជាក់ពីនាយកដ្ឋានពេទ្យការងារ និងបង់សេវាសាធារណៈចំនួន ២០.០០០ (ម្ភៃពាន់) រៀល ជូននាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈតាមប្រព័ន្ធទិន្នន័យស្វ័យប្រវត្តិកម្មនេះជាមុន។

**ប្រការ ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធាននាយកដ្ឋានមុខរបរនិងហត្ថពលកម្ម ប្រធាននាយកដ្ឋានពេទ្យការងារ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦*

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-សាលារាជធានី ខេត្ត
*"ដើម្បីជូនជ្រាប"*
-ដូចប្រការ ៦
*"ដើម្បីអនុវត្ត"*
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ